ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសេចក្តីសោមនស្សជម្រាបជូនសាធារណជនជ្រាបថា នៅឆ្នាំ២០២៣នេះ តម្លៃស្រូវនៅទីវាល ជាពិសេសប្រភេទពូជស្រូវប្រាំង IR និង OM មានតម្លៃខ្ពស់មិនធ្លាប់មាន នៅក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ។ យោងតាមតម្លៃស្រូវនៅទីវាលដែលប្រមូលដោយសហព័ន្ធស្រូវអង្ករកម្ពុជា នៅក្នុងឆ្នាំ២០២៣នេះ ស្រូវប្រភេទ IR មានតម្លៃ ១ ០៤៧រៀល/គ.ក្រ ខណៈស្រូវប្រភេទ OM មានតម្លៃ ១ ០២៩រៀល/គ.ក្រ។ ចំណែកឯប្រភេទពូជស្រូវសែនក្រអូបវិញ គឺមានតម្លៃខ្ពស់ជាងគេបើធៀបនឹងប្រភេទពូជស្រូវ IR និង OM ប៉ុន្តែតម្លៃស្រូវសែនក្រអូបមិនសូវមានការប្រែប្រួលទេ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ដោយជាមធ្យម មានតម្លៃចន្លោះពី ១០០០-១២៦០រៀល/គ.ក្រ។

ក្រៅតែពីថ្លៃស្រូវមានស្ថានភាពល្អប្រសើរ តម្លៃជីកសិកម្ម ចាប់តាំងពីខែមករា ឆ្នាំ២០២៣ រហូតមកទល់ពេលនេះ មានការធ្លាក់ចុះជាបន្តបន្ទាប់ ក្នុងនោះ ជីអ៊ុយរ៉េ ធ្លាក់ថ្លៃពី ៣៥ដុល្លារ/បាវ មកនៅត្រឹម ២៣,៥ដុល្លារ/បាវ ខណៈជីដេអាប៉េ (DAP: 18-46-0) ធ្លាក់ថ្លៃពី ៤២ដុល្លារ/បាវ មកនៅត្រឹម ៣៦ដុល្លារ/បាវ។ លើសពីនេះទៀត តម្លៃថ្នាំកសិកម្មមួយចំនួនក៏ថយចុះផងដែរ ដូចជា ថ្នាំកម្ចាត់ស្មៅឈ្មោះ Atrazine 80% WP បានថយចុះ ៣៥% ថ្នាំកម្ចាត់ស្មៅឈ្មោះ Glyphosate 48% SL និង 2.4. D 72% SL បានថយចុះក្នុងកម្រិតពី ២១% ដល់ ២៣% ថ្នាំកម្ចាត់ជំងឺឈ្មោះ Mancozeb 80% WP បានថយចុះ ១៤% ថ្នាំសម្លាប់សត្វល្អិត ឈ្មោះ Acephate បានថយចុះប្រមាណ ៦% ខណៈពេលដែលប្រភេទថ្នាំកសិកម្មផ្សេងទៀតមានការប្រែប្រួលតម្លៃតិចតួច។

លទ្ធផលនេះកើតចេញពីការចូលរួមចំណែក និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងស្ថាប័នពាក់ព័ន្ធ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការទម្លាក់ថវិកាទាន់ពេលវេលា សម្រាប់អន្តរាគមន៍ទប់ទល់នឹងការធ្លាក់ចុះតម្លៃស្រូវក្នុងរដូវប្រមូលផល ការសម្រួលការនាំចេញស្រូវ-អង្ករ និងការបើកឱកាសប្រកួតប្រជែងលើទីផ្សារសម្រាប់ជីនិងថ្នាំកសិកម្មដែលមានគុណភាព។

ថ្ងៃសុក្រ ៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

# តម្លៃមធ្យមស្រូវអ៊ីអ៊ែរ (IR) ប្រចាំខែនីមួយៗក្នុងឆមាសទី១ ចាប់ពីឆ្នាំ ២០២០ - ២០២៣
(គិតជារៀលក្នុងមួយគីឡូក្រាម)




# តម្លៃមធ្យមស្រូវអូអឹម (OM) ប្រចាំខែនីមួយៗក្នុងឆមាសទី១ ចាប់ពីឆ្នាំ ២០២០ - ២០២៣
(គិតជារៀលក្នុងមួយគីឡូក្រាម)



## តម្លៃមធ្យមស្រូវសែនក្រអូបប្រចាំខែនីមួយៗក្នុងឆមាសទី១ ចាប់ពីឆ្នាំ ២០២០ - ២០២៣
## (គិតជារៀលក្នុងមួយគីឡូក្រាម)



## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## អគ្គនាយកដ្ឋានកសិកម្ម
## នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម

### ក្រាហ្វិកបម្រែបម្រួលតម្លៃជីកសិកម្ម UREA ( 46-0-0 ) ឆ្នាំ២០២២-២០២៣ ( គិតជា USD/បាវ )




### ក្រាហ្វិកបម្រែបម្រួលតម្លៃជីកសិកម្ម DAP ( 18-46-0 ) ឆ្នាំ២០២២-២០២៣ ( គិតជា USD/បាវ )



# ក្រាហ្វិចប្រៀបធៀបតម្លៃរបស់ថ្នាំកសិកម្ម







តម្លៃប្រែប្រួល Glufosinate ឆ្នាំ២០២៣ ( ដល់ខែមិថុនា )
9200
9000
8800
8600
8400
8200
8000
7800
7600
7400
9000
9000
8000
8000
ធ្នូ២០២២
មករា-កុម្ភៈ
មីនា-មេសា
ឧសភា-មិថុនា


តម្លៃប្រែប្រួល 2.4. D ឆ្នាំ២០២៣ ( ដល់ខែមិថុនា )
6000
5000
4000
3000
2000
1000
0
4900
4444
3889
3889
ធ្នូ២០២២
មករា-កុម្ភៈ
មីនា-មេសា
ឧសភា-មិថុនា


តម្លៃប្រែប្រួល Acephate ឆ្នាំ២០២៣ ( ដល់ខែមិថុនា )
12800
12600
12400
12200
12000
11800
11600
11400
12600
12600
12600
11900
ធ្នូ២០២២
មករា-កុម្ភៈ
មិនា-មេសា
ឧសភា-មិថុនា


តម្លៃប្រែប្រួល Moncozeb ឆ្នាំ២០២៣ ( ដល់ខែមិថុនា )
7200
7000
6800
6600
6400
6200
6000
5800
5600
5400
6950
6000
6000
6000
ធ្នូ២០២២
មករា-កុម្ភៈ
មិនា-មេសា
ឧសភា-មិថុនា